**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៨៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១:-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ សរសេរកាត់ "ម.ប.វ.អ.ព" ចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា ។

**មាត្រា២:-**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារមានឋានៈស្មើនាយកដ្ឋាន ។ មជ្ឈមណ្ឌលនេះដឹកនាំដោយនាយក មួយរូប និង នាយករងមួយចំនួន ជាជំនួយ តាមការចាំបាច់ ។

**មាត្រា៣ៈ-**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ មានតួនាទីជាសេនាធិការជូនបណ្ឌិត្យសភានគរបាលកម្ពុជា លើការងារបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ កម្រិតមធ្យម (បរិញ្ញាបត្ររង) និង ធ្វើវិក្រឹតការ សុក្រឹតការជំនាញឯកទេស ជូនមន្ត្រីអនុរក្ស និង ថ្នាក់ដឹកនាំពន្ធនាគារគ្រប់កម្រិត ។

បណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារក្នុងការរៀបចំកម្មវិធីសិក្សាកម្រិតមធ្យមវិជ្ជាជីវៈអនុរក្សពន្ធនាគារ ដោយមានការឯកភាពពី ក្រសួងមហាផ្ទៃ និង មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៤ៈ-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា កម្រិតមធ្យម(បរិញ្ញាបត្ររង)វិជ្ជាជីវៈអនុរក្សពន្ធនាគារ និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ បរិញ្ញាបត្ររង តាមមុខជំនាញឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ នឹងចុះហត្ថលេខាដោយ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៥ៈ-**

លក្ខខណ្ឌនៃការជ្រើសរើសសិស្ស និស្សិត ឱ្យចូលរៀន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាមបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៦ៈ-**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារមានភារកិច្ច ដូចតទៅ :

- សហការជាមួយអង្គភាពពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការរៀបចំផែនការបណ្តុះបណ្តាល និង កម្មវិធី វិក្រឹតការ សុក្រឹតការជំនាញឯកទេស ជូនមន្ត្រីអនុរក្ស និង ថ្នាក់ដឹកនាំពន្ធនាគារគ្រប់ កម្រិត
- សិក្សាស្រាវជ្រាវធ្វើទំនើបកម្មរូបនីយកម្មខ្លឹមសារបង្ហាត់បង្រៀន កម្មវិធីសិក្សា និង កម្មសិក្សាប្រតិបត្តិ
- ចាត់វិធានការអនុវត្តផែនការបណ្តុះបណ្តាល តាមកម្មវិធីរបស់ បណ្ឌិត្យសភានគរបាលកម្ពុជា និង ក្រសួងមហាផ្ទៃ
- លើកគម្រោងផែនការថវិកា សម្ភារៈ របស់មជ្ឈមណ្ឌល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដំណើរការសិក្សា តាមការកំណត់របស់ បណ្ឌិត្យសភានគរបាលកម្ពុជា និង ក្រសួងមហាផ្ទៃ
- បូកសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ជូនបណ្ឌិត្យសភានគរបាលកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឱ្យ ។

**មាត្រា៧:-**

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច អង្គភាពចំណុះមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៨:-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា៩*

*-ឯកសារ-កាលប្បវត្តិ*